# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ១៥៩.សរណ-៩៩

## ប្រធានតុលាការកំពូល

**<u>ជម្រាបមក</u>**

**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**<u>សូមជ្រាប។</u>**

**<u>កម្មវត្ថុ:</u>** ការយឺតយ៉ាវក្នុងការចាត់ការរឿងព្រហ្មទណ្ឌដល់អង្គសេចក្តី នៅពេលមានការប្តឹងតវ៉ា អំពីដីកាឃុំខ្លួនជាបណ្តោះអាសន្ន ឬ ដីកាដោះលែងឱ្យនៅក្រៅឃុំរបស់ចៅក្រមស៊ើបអង្កេត ។

តុលាការកំពូល បានកត់សម្គាល់ឃើញថា នៅពេលមានការប្តឹងតវ៉ាអំពីដីកាឃុំខ្លួនជាបណ្តោះអាសន្នអំពីដីកាឱ្យនៅក្រៅឃុំរបស់ចៅក្រមស៊ើបអង្កេត នៃតុលាការខេត្ត-ក្រុងៗតែងតែបញ្ជូនសំណុំរឿងដើមទាំងមូលមកសាលាឧទ្ធរណ៍ ហើយបន្តបញ្ជូនមកតុលាការកំពូលទៀត ដូច្នេះការស្រាវជ្រាវស៊ើបអង្កេត និងសម្រេចរឿងដល់អង្គសេចក្តីត្រូវផ្អាករង់ចាំសំណុំរឿងបញ្ជូនត្រឡប់ទៅវិញ ជាញឹកញយការឃុំខ្លួនបណ្តោះអាសន្នត្រូវហួសកំណត់ពេលអនុញ្ញាតការធ្វើដូច្នេះទាំងមានការយឺតយ៉ាវក្នុងការដោះស្រាយរឿងដល់អង្គសេចក្តី ។

តុលាការកំពូលយល់ឃើញថា តុលាការខេត្ត-ក្រុងគប្បីចាត់ការថតចម្លងឯកសារ ដែលមានក្នុងសំណុំរឿងដើមហើយបញ្ជូនមកសាលាឧទ្ធរណ៍ តែសំណុំរឿងថតចម្លងបានហើយទន្ទឹមនេះក៏ត្រូវដោះស្រាយរឿងតាមកាលកំណត់ ។

សេចក្តីដូចបានជម្រាបជូននេះ សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាពិនិត្យ និង សម្រេច បើមិនយល់ទាស់ទេសូមមេត្តាចាត់ការ ណែនាំទៅបណ្តាតុលាការខេត្ត-ក្រុង ចំពោះសំណើនេះតាមការគួរ ។

សូម **ឯកឧត្តម** ទទួលនូវការគោរពអំពីខ្ញុំ

ធ្វើនៅភ្នំពេញ ថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩